**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង រៀបចំគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨១ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមប្រឹក្សារៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួងរៀបចំគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង សរសេរជាអក្សរកាត់ថា **គ.ប.ជ.**។

## ជំពូកទី២
## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា២ .-**

**គ.ប.ជ.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១០- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១(មួយ)រូប | សមាជិក |
| ១២- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១(មួយ)រូប | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១(មួយ)រូប | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងការពារជាតិ ១(មួយ)រូប | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១(មួយ)រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១(មួយ)រូប | សមាជិក |
| ១៧- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១(មួយ)រូប | សមាជិក |

១៨- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១(មួយ)រូប	សមាជិក

១៩- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១(មួយ)រូប	សមាជិក

២០- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១(មួយ)រូប	សមាជិក

២១- រដ្ឋលេខាធិការក្រសួងសុខាភិបាល ១(មួយ)រូប	សមាជិក

២២- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ១(មួយ)រូប	សមាជិក

២៣- ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា ១(មួយ)រូប	សមាជិក

២៤- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ១(មួយ)រូប	សមាជិក

២៥- អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ	សមាជិក។

ក្រៅពីសមាជិកខាងលើនេះ **គ.ប.ដ.** អាចស្នើឱ្យតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតចូលរួមជាសមាជិកតាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **គ.ប.ដ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

**គ.ប.ដ.** អាចមានគណៈកម្មការឬក្រុមការងារបច្ចេកទេសផ្សេងៗ តាមតម្រូវការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការឬក្រុមការងារបច្ចេកទេសនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ប.ដ.**។

## ជំពូកទី៣
## តួនាទីនិងភារកិច្ច

**មាត្រា៤ .-**

**គ.ប.ដ.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ដឹកនាំនិងសម្របសម្រួលអន្តរក្រសួង ស្ថាប័នក្នុងការរៀបចំគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង
- ផ្តល់ការណែនាំជាយុទ្ធសាស្ត្រនិងបច្ចេកទេសក្នុងការរៀបចំគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង
- តាមដាននិងត្រួតពិនិត្យវឌ្ឍនភាពនៃការរៀបចំគោលនយោបាយ
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការរៀបចំគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ជូនក្រុមប្រឹក្សារៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង
- ធ្វើកិច្ចសហប្រតិបត្តិការបច្ចេកទេសនិងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ប្រធាន **ក.ផ.ស.**។

## ជំពូកទី៤
## ការប្រព្រឹត្តទៅ

**មាត្រា៥ .-**

អនុប្រធាននិងសមាជិក **គ.ប.ដ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមានឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានមួយរូប ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៦ .-**

**គ.ប.ជ.** មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន អាជ្ញាធរ និងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័ន ពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំតាមការចាំបាច់។

**គ.ប.ជ.** មានសិទ្ធិអញ្ជើញដៃគូអភិវឌ្ឍ តំណាងវិស័យឯកជន តំណាងសមាគម អង្គការមិនមែនរដ្ឋាភិបាល ទីប្រឹក្សា ឬអ្នកជំនាញការជាតិនិងអន្តរជាតិ ចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍ឬអ្នកផ្តល់យោបល់តាមការចាំបាច់។

**មាត្រា៧ .-**

**គ.ប.ជ.** មានអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិជាសេនាធិការសម្រាប់បំពេញមុខងាររបស់ខ្លួន។

ក្នុងតួនាទីជាសេនាធិការរបស់ **គ.ប.ជ.** អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ប្រើមន្ត្រីក្របខណ្ឌមុខងារសាធារណៈ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យជួយបំពេញការងាររបស់ខ្លួន ក្រោមឱវាទរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៨ .-**

ក្នុងតួនាទីជាសេនាធិការរបស់ **គ.ប.ជ.** អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ មានភារកិច្ចដូចតទៅ៖

- ប្រមូល ចងក្រង និងវិភាគទិន្នន័យនិងព័ត៌មាន ក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង
- ធ្វើកិច្ចសហប្រតិបត្តិការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍនិងតួអង្គពាក់ព័ន្ធនានាក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយ
- រៀបចំសិក្ខាសាលានិងកិច្ចប្រជុំពិគ្រោះយោបល់លើការងាររៀបចំសេចក្តីព្រាងគោលយោបាយ
- រៀបចំកំណត់ហេតុកិច្ចប្រជុំនិងរបាយការណ៍ស្តីពីវឌ្ឍនភាពការងាររបស់ **គ.ប.ជ.**
- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ប.ជ.** ស្របតាមការណែនាំនិងការសម្រេចរបស់ប្រធាន **គ.ប.ជ.**
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធាន **គ.ប.ជ.**។

**មាត្រា៩ .-**

**គ.ប.ជ.** ប្រើត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់បំពេញការងាររបស់ខ្លួន។

## ជំពូកទី៥

## ហិរញ្ញវត្ថុ

**មាត្រា១០ .-**

**គ.ប.ជ.** ប្រើកញ្ចប់ថវិការបស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

គណៈកម្មការឬក្រុមការងារនានាក្រោមឱវាទ **គ.ប.ជ.** អាចមានសិទ្ធិប្រើធនធាននិងថវិការបស់ក្រសួង ស្ថាប័នដែលមានភារកិច្ចដឹកនាំគណៈកម្មការឬក្រុមការងារនីមួយៗ។

**គ.ប.៤.** មានសិទ្ធិទទួលនិងគ្រប់គ្រងតាមនីតិវិធីដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាធរមាននូវមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិនិងពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៤ កើត ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ